ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល លេខ ៤៣៣៤
ថ្ងៃទី ២៥ . ១០ . ១៣
ម៉ោង

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/១០០៥

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងសមាជិកក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ) និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន ក.ក.ជ ÷

១. ឯកឧត្តម **អ៊ិត ណូឌី** ជាសមាជិក ក.ក.ជ ឋានៈស្មើ រដ្ឋមន្ត្រី

២. ឯកឧត្តម **រ័ត្ន ទិរៈ** ជាសមាជិក ក.ក.ជ ឋានៈស្មើ រដ្ឋមន្ត្រី

៣. ឯកឧត្តម **ជ័យ សាខន្ធ** ជាសមាជិក ក.ក.ជ ឋានៈស្មើ រដ្ឋមន្ត្រី

៤. ឯកឧត្តម **ឡៅ សុខារម្ភ** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក.ក.ជ ឋានៈស្មើ រដ្ឋលេខាធិការ

៥. ឯកឧត្តម **នៅ ពន្លក** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ក.ជ ឋានៈស្មើ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៦. ឯកឧត្តម កៅ មួយថង ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ក.ជ ឋានៈស្មើអនុរដ្ឋលេខាធិការ

៧. ឯកឧត្តម ទណ្ឌ សុផាណ្ណា ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ក.ជ ឋានៈស្មើអនុរដ្ឋលេខាធិការ

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣១០.១០១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ៩៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុ៣ ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

លេខ : ៦៧៩ ចល.កសក
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក:
-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
" ដើម្បីជូនជ្រាប "
-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
" ដើម្បីផ្សព្វផ្សាយ "
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ២០១៣
**ត.ប រដ្ឋមន្ត្រី**
**អគ្គលេខាធិការ**